ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

**គណៈកម្មាធិការលទ្ធកម្ម ( គ.លក-PC )**
**លេខ: ០០២ /២៥ ស.ជ.ណ**

ថ្ងៃព្រហស្បតិ៍ ៣កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៥

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រចាំឆ្នាំ២០២៥ សម្រាប់រាជបណ្ឌិត្យសភាកម្ពុជា

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ សម្រាប់ការផ្គត់ផ្គង់ប្រេងឥន្ធនៈប្រចាំឆ្នាំ២០២៥។

រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅ អង្គភាពលទ្ធកម្ម រាជបណ្ឌិត្យសភាកម្ពុជា ដែលមានអាសយដ្ឋាននៅ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ (អគារខេមរិទូ ជាន់ទី១) ចាប់ពីថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៥ រៀងរាល់ម៉ោងធ្វើការ ( ទូរសព្ទទាក់ទងលេខ: ០២៣ ៨៩០ ១៨០ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១៥:០០ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២៥។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥:០០ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២៥។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ អង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**និងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

ចម្លងជូន៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ « អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ»
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ